**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០០៤/១៨ ក.ប/ស.ជ.ណ.ល.ស.ស

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលដល់កម្មករនិយោជិតជាស្ត្រី ទាំងក្នុងនិងក្រៅប្រព័ន្ធ ពេលសម្រាលកូនដែលបានចុះបញ្ជីរួច ក្នុងបេឡាជាតិរបបសន្តិសុខសង្គម**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន និង បុគ្គលិក កម្មករ និយោជិត ទាំងក្នុងនិងក្រៅប្រព័ន្ធ ដែលបានចុះបញ្ជីរួចនៅប.ស.ស ឲ្យបានជ្រាបថា ដើម្បីអនុវត្តអនុសាសន៍ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចាប់ពីម៉ោងសូន្យ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៧ មក បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) បាននិងកំពុងបើកផ្តល់ប្រាក់ឧបត្ថម្ភបន្ថែមរបស់រាជរដ្ឋាភិបាលដល់កម្មករនិយោជិតទាំងក្នុងនិងក្រៅប្រព័ន្ធពេលសម្រាលកូនទូទាំង ២៥ រាជធានី-ខេត្ត។ ជាមួយគ្នានេះ ប.ស.ស បានរកឃើញបញ្ហាប្រឈមមួយចំនួនក្នុងការបើកផ្តល់ប្រាក់ឧបត្ថម្ភ ដែលកន្លែងមួយចំនួនមានភាពយឺតយ៉ាវ ដោយមូលហេតុខ្វះឯកសារ និងខ្វះការផ្តល់ព័ត៌មានអំពីការសម្រាលកូន ។ ដើម្បីបើកផ្តល់ប្រាក់ឧបត្ថម្ភនេះឲ្យបានកាន់តែលឿន និងមានប្រសិទ្ធភាពខ្ពស់ជូនកម្មករនិយោជិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមធ្វើការណែនាំអំពីបែបបទ និងនីតិវិធីមួយចំនួន ដល់និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថាន បុគ្គលិក កម្មករ និយោជិត និងមូលដ្ឋានសុខាភិបាល ដូចខាងក្រោមៈ

ទី១.សាមីខ្លួនត្រូវភ្ជាប់មកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនិងលេខទូរស័ព្ទច្បាស់លាស់។

ទី២.សាមីខ្លួនត្រូវភ្ជាប់មកតាមខ្លួននូវប័ណ្ណសមាជិកប.ស.ស ឬប័ណ្ណមូលនិធិសមធម៌សុខាភិបាល។

ទី៣.សាមីខ្លួន ឬសាច់ញាតិរបស់ខ្លួន ត្រូវជូនដំណឹងមក ប.ស.ស តាមរយៈលេខទូរស័ព្ទទំនាក់ទំនងបន្ទាន់ ១២៨៦ ពេលចូលទៅសម្រាលកូនក្នុងមន្ទីរពេទ្យ ដែលគ្មានភ្នាក់ងារ ប.ស.ស។

ទី៤.ស្នើមូលដ្ឋានសុខាភិបាលទាំងអស់ ផ្តល់កិច្ចសហការ និងព័ត៌មាន ដល់មន្ត្រី សាខា ប.ស.ស នៅតាមស្នាក់ការ ប.ស.ស រាជធានី ខេត្ត ខណ្ឌ អំពីការទៅទទួលសេវាសម្រាលកូនក្នុងមូលដ្ឋានសុខាភិបាលរបស់ខ្លួន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា និយោជក ម្ចាស់សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវផ្សព្វផ្សាយបន្តដល់កម្មករនិយោជិតរបស់ខ្លួន និងស្នើដល់បងប្អូន កម្មករ និយោជិត ទាំងអស់ឲ្យចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ១១រោច ខែ បុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩